ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សក MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៤៤ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## បដិប្បញ្ញត្តិចំពោះការហាមឃាត់មិនអោយប្រើ ក្មេងធ្វើការពេលយប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ក្មេងដែលមានអាយុពី១៦ឆ្នាំទៅក្រោម១៨ឆ្នាំ អាចប្រើអោយធ្វើការនៅពេលយប់បាននៅក្នុងរោងចក្រស្លដែក និងដែកថែប រោងចក្រធ្វើកែវ រោងចក្រធ្វើក្រដាស រោងចក្រធ្វើស្ករ និងរោងចក្របំបែករ៉ែមាស ដែលត្រូវដើរគតឈប់ទាំងយប់ទាំងថ្ងៃ ។ ការប្រើក្មេងអោយធ្វើការពេលយប់នៅក្នុងរោងចក្រទាំងនេះមានគោលបំណងតែមួយគឺ ដើម្បីផ្តល់ការហ្វឹកហ្វឺន ឬបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្មេងតែប៉ុណ្ណោះ ។

**ប្រការ២.-** ក្នុងគ្រប់ករណីទាំងអស់ថិរវេលាធ្វើការប្រចាំថ្ងៃរបស់ក្មេង មិនអាចលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ ហើយ

ការសំរាករបស់ក្មេងនៅចន្លោះពីម៉ោងធ្វើការមួយទៅម៉ោងធ្វើការមួយទៀត ត្រូវមានថិរវេលាយ៉ាងហោច ណាស់ ១៣ ម៉ោងជាប់គ្នា ។

**ប្រការ៣.**- និយោជកដែលចង់ប្រើក្មេងពេលយប់ ត្រូវសុំការអនុញ្ញាតជាមុនពីអធិការការងារ ។ បន្ទាប់ពីបានទទួលពាក្យស្នើសុំហើយ អធិការការងារត្រូវធ្វើការសំរេចតាមករណីក្មេងនិមួយៗ ដោយផ្អែកតាមមូលហេតុ នៃការប្រើក្មេង ថិរវេលាធ្វើការ និងការសំរាករបស់ក្មេង ព្រមទាំងវិញ្ញាបនប័ត្រកាយសម្បទារបស់ក្មេង ដែលចេញដោយគ្រូពេទ្យការងារផង ។

**ប្រការ៤.**- នៅក្នុងគ្រឹះស្ថាន សហគ្រាសទាំងអស់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ និយោជកអាចប្រើក្មេងប្រុសអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អោយធ្វើការនៅពេលយប់បាន ដើម្បីជួយបង្ការគ្រោះថ្នាក់ដែលអាចនឹងកើតមាន ឬដើម្បីជួសជុលគ្រឿងចក្រ បរិក្ខា ឬសម្ភារៈដែលខូចខាតបណ្តាលមកពីមានគ្រោះថ្នាក់កន្លងមកហើយ ។ និយោជកដែលចង់ប្រើក្មេងក្នុងគោលបំណងខាងលើ ត្រូវជូនដំណឹងអោយអធិការការងារបានដឹងជាមុនអំពីមូលហេតុ នៃការធ្វើបដិប្បញ្ញត្តិនេះ ។

**ប្រការ៥.**- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៨ សកអ.ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.**- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សហគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

គ្រប់អង្គភាពវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"

- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ